រាជរដ្ឋាភិបាលកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល

*រាជរដ្ឋាភិបាល* សូមជម្រាបជូនសាធារណមតិជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៧ វេលាម៉ោង ០០:៣៥ នាទី នេះ ឈ្មោះ កឹម សុខា ត្រូវបានចាប់ខ្លួន ដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងបទល្មើសជាក់ស្តែង ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

*រាជរដ្ឋាភិបាល* សូមជម្រាបជូនថា តាមរយៈវីដេអូឃ្លីប ដែលត្រូវបានផ្សព្វផ្សាយដោយបណ្តាញ CBN (Cambodian Broadcasting Network) ដែលមានទីតាំងនៅអូស្ត្រាលី និងភស្តុតាងដទៃទៀតដែលអាជ្ញាធរមានសមត្ថកិច្ចប្រមូលបាន គឺបានបង្ហាញឱ្យឃើញច្បាស់អំពីផែនការសម្ងាត់នៃការឃុបឃិតគ្នារវាងឈ្មោះ កឹម សុខា និងបក្សពួក ជាមួយបរទេស ដែលធ្វើឱ្យប៉ះពាល់ដល់ព្រះរាជាណាចក្រកម្ពុជា។ អំពើនៃការឃុបឃិតគ្នាជាសម្ងាត់ខាងលើនេះ គឺជាអំពើក្បត់ជាតិ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៤៤៣ (បទសន្ធិជ្ជិភាពជាមួយបរទេស) ក្នុងផ្នែកទី ១ ស្តីពីអំពើក្បត់ជាតិ និងអំពើចារកម្ម ជំពូកទី ២ ស្តីពីការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ មាតិកាទី១ ស្តីពីការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ គន្ថីទី៤ ស្តីពីបទល្មើសប្រឆាំងនឹងជាតិ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ វីដេអូឃ្លីបខាងលើនេះ ក៏កំពុងតែបន្តផ្សព្វផ្សាយរហូតមកដល់ពេលនេះផងដែរ។ បច្ចុប្បន្ន ឈ្មោះ កឹម សុខា ស្ថិតនៅក្រោមការឃាត់ខ្លួន និងការចាត់ការតាមច្បាប់ ដោយស្ថាប័នមានសមត្ថកិច្ចនិងស្ថាប័នតុលាការ។

*រាជរដ្ឋាភិបាល* សូមអំពាវនាវឱ្យរក្សាភាពស្ងប់ស្ងាត់ និងទុកករណីនេះ ជូនតុលាការដើម្បីចាត់ការបន្តជាសមត្ថកិច្ចស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

អាស្រ័យហេតុនេះ សូមសាធារណមតិជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៧*